ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

# បទសម្ភាសន៍ជាមួយលោកជំទាវ បណ្ឌិត ស៊ីន ជុំបូ ជាអនុប្រធាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅក្នុងឱកាសទិវាសិទ្ធិនារីអន្តរជាតិ

**( បទសម្ភាសន៍នេះធ្វើឡើងនៅថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០០៧ )**

*លោកជំទាវបណ្ឌិត ស៊ីន ជុំបូ គឺជាអនុប្រធាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាំងពី ខែកក្កដា ឆ្នាំ ២០០៦ មក។ មុនពេលដែលលោកជំទាវបណ្ឌិតត្រូវបានបោះឆ្នោតតែងតាំងជាសមាជិក គ.ជ.ប នៅខែ តុលា ឆ្នាំ ២០០២ លោកជំទាវបានចុះធ្វើបេសកកម្មផ្តល់ទីប្រឹក្សា ក្នុងវិស័យយ៉េនឌ័ និង អប់រំ។ មុនទិវាសិទ្ធិនារីអន្តរជាតិ មួយថ្ងៃ និង នៅសល់ប្រមាណ ពីរ បី សប្តាហ៍នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី២ ខាងមុខនេះ លោកជំទាវបណ្ឌិត បានទទួលការចូលរួមផ្តល់ យោបល់ អំពីស្ថានភាពរបស់ស្ត្រីនៅក្នុងសង្គម និងក្នុងនយោបាយ។*

**សំណួរ ៖ ស្ត្រីកាន់តែច្រើនទៅៗ បានប្រឡូកក្នុងនយោបាយ ជាពិសេសក្នុងការបោះឆ្នោត ឃុំ សង្កាត់ខាងមុខនេះ។ ក្នុងចំណោមបេក្ខជន ១០២.២២៦ រូប មានស្ត្រីចំនួន ២១.៨៤០ រូប ស្មើនឹង ២១.៣៥% ដែលខុសពីប្រាំឆ្នាំមុន ដែលមានចំនួនតែ ១៦%។ ពិនិត្យលើស្ថានភាពនេះ តើលោកជំទាវបណ្ឌិតមានអារម្មណ៍យ៉ាងដូចម្តេចដែរ? តើលោកជំទាវកត់សំគាល់ឃើញនូវការវិវត្តន៍ណាមួយដែរឬទេ?**

**ចម្លើយ ៖** ជាការពិតណាស់ ស្ថានភាពនេះកំពុងតែឈានទៅរកគោលដៅដ៏ល្អមួយ។ ស្ត្រីកាន់តែច្រើនទៅៗបានចុះឈ្មោះជាបេក្ខនារីក្នុងការបោះឆ្នោតនាថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៧ ខាងមុខនេះ ក៏ប៉ុន្តែទន្ទឹមនឹងនេះ យើងឃើញមិនមានស្ត្រីច្រើនទេដែលត្រូវបានជាប់ឈ្មោះនៅខាងលើគេក្នុងបញ្ជីបេក្ខជន។ ទោះជាយ៉ាងនេះក្តី ក៏ទិន្នន័យនេះជាការលើកទឹកចិត្តចំពោះយើងមួយដែរ។

ការវិវត្តន៍នៅក្នុងនយោបាយនេះ ឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរមួយចំនួននៅក្នុងសង្គមយើង។ ស្ត្រីទទួលបាននូវការអប់រំកាន់តែច្រើន និងបំពេញការងារដោយមានការទទួលខុសត្រូវយ៉ាងងាយស្រួល។ ឯក្រសួងកិច្ចការនារី និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗទៀត ក៏បានសម្រេចការងារ ដ៏គួរអោយកត់សំគាល់ តាមរយៈកម្មវិធីជួយអោយស្ត្រីបានយល់ដឹងអំពីតំលៃនៃការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងនយោបាយក្នុងប្រទេស។ បច្ចុប្បន្ននេះ មានស្ត្រីខ្មែរមាន

សមត្ថភាពខ្ពស់ជាអ្នកដឹកនាំច្រើនជាងមុន។ ស្ត្រីជាច្រើនមិនមានការស្ទាក់ស្ទើរ ក្នុងការបញ្ចេញមតិក្នុងវេទិកាសាធារណៈ ឬក៏ការប្រជុំផ្សេងៗឡើយ។

ក្នុងឆ្នាំ២០០២ គណបក្សប្រជាជនមានបេក្ខនារីចំនួន ១៣.១៥% ហើយគណបក្សហ៊្វុនស៊ិនប៉ិចមានចំនួន ១៣.៧៤% នៅក្នុងបញ្ជី ដែលគិតជាមធ្យមភាគជាតិប្រហែល១៦%។ ចំពោះការបោះឆ្នោតខាងមុខនេះ គណបក្សទាំងពីរ បានបន្ថែមសមាមាត្រលើស្ត្រី ពី ១៩.៩៨% និង ២៣.៨៦%នៅក្នុងបញ្ជីរៀងៗខ្លួន។ ក៏ប៉ុន្តែតួលេខ ក៏បានបង្ហាញផងដែរថា គណបក្សសម រង្ស៊ី ដែលមានស្ត្រីឈរឈ្មោះជាបេក្ខនារីចំនួន ២០.៤០% ក្នុងមធ្យមភាគជាតិឆ្នាំ ២០០២ បានធ្លាក់មកត្រឹម ១៦.០៩% ក្នុងឆ្នាំ ២០០៧នេះ។ ខ្ញុំមិនមានការពន្យល់អ្វីទេ ដោយសារតែខ្ញុំមិនស្ថិតនៅក្នុងបរិវេណគណបក្សនយោបាយ ប៉ុន្តែខ្ញុំអាចបញ្ជាក់បានថា និន្នាការជារួមនេះ ជាការជំរុញទឹកចិត្តមួយ ហើយខ្ញុំសង្ឃឹមយ៉ាងមុតមាំថានៅក្នុងការបោះឆ្នោតសកលនាឆ្នាំ ២០០៨ ខាងមុខនេះ យើងសំណូមពរ ឱ្យមានការកើនចំនួនបេក្ខនារី ឈានដល់សមាមាត្រ ៣០% ដូចដែលការគាំទ្រពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល និងក្រុមស្ត្រីនានាចង់បាន។

គ.ជ.ប ស្វាគមន៍នូវការចូលរួមពីសំណាក់ស្ត្រីក្នុងនយោបាយអោយបានទូលំទូលាយ។ ជាអកុសល គ.ជ.ប មិនមានបេសកកម្មបណ្តុះបណ្តាលផ្ទាល់ដល់ស្ត្រី ដើម្បីពង្រីកការចូលរួមនេះ ពីព្រោះយើងស្ថិតនៅក្នុងរង្វង់ច្បាប់ និងគ្រាន់តែជាអ្នកទទួលចុះឈ្មោះបញ្ជីបេក្ខជន បេក្ខនារី តែប៉ុណ្ណោះ...

**សំណួរ ៖ គួរកត់សំគាល់ថា នៅរាជធានីភ្នំពេញ បេក្ខជនដែលឈរឈ្មោះបោះឆ្នោតខាងមុខនេះ ជាស្ត្រីដែលមានចំនួនលើសពីមួយភាគបី ក្នុងចំណោមបេក្ខជនទាំងអស់ (៣៥.០៨%)។ ជាទូទៅការផ្លាស់ប្តូរនេះមាននៅទីក្រុង តើលោកជំទាវបណ្ឌិត ឯកភាពនឹងមតិនេះដែរឬទេ? ប៉ុន្តែ តើលោកជំទាវបណ្ឌិតបានសង្កេតមើលបាតុភូតស្រដៀងគ្នានេះនៅតាមទីជនបទដែរឬទេ ?**

**ចម្លើយ ៖** វាជាការកត់សំគាល់ដ៏ល្អមួយដែរ ដែលស្ត្រីជាច្រើនមានចំណាប់អារម្មណ៍ទៅនឹងការចូលរួមប្រឡូកក្នុងរឿងនយោបាយ។ មធ្យមភាគជាតិលើវត្តមានរបស់ស្ត្រីក្នុងបញ្ជីបេក្ខជន គឺមានចំនួនប្រមាណ ២១%។ ជារួមនៅគ្រប់តំបន់ប្រជុំជនទាំងអស់ សមាមាត្ររបស់ស្ត្រីមានចំនួនលើសពីមធ្យមភាគ មិនមែនតែនៅក្នុងទីក្រុងប៉ុណ្ណោះទេ។ នៅប៉ៃលិន ឬក៏នៅខេត្តបាត់ដំបង ចំនួនសមាមាត្រនេះលើសពី ២៧%។ នៅទីក្រុង ប្រជាពលរដ្ឋមានចំណេះដឹងច្រើន ព្រោះពួកគេអាចទទួលបានចំណេះដឹងយ៉ាងងាយ តាមរយៈការរីកចំរើននៃព័ត៌មានវិទ្យាច្រើនរូបភាព។ ការទទួលការអប់រំច្រើនមានន័យថា ធ្វើឱ្យស្ត្រីទទួលបាននូវភាពជឿជាក់លើខ្លួនឯងយ៉ាងច្រើន និងបង្កើនសមត្ថភាពកាន់តែខ្ពស់ឡើង ក្នុងការបញ្ចេញមតិ។ ប៉ុន្តែ ទោះជាមានភាពខុសគ្នាក្នុងការទទួលព័ត៌មានក៏ដោយ ក៏អត្តចរិករបស់ស្ត្រីនៅក្នុងទីក្រុង និងជនបទមិនមានភាពខុសគ្នាឆ្ងាយពេកទេ។ ស្ត្រីនៅគ្រប់ទីកន្លែងបានបញ្ចេញសំលេងរបស់ខ្លួន និងមិនខ្លាចក្នុងការបញ្ចេញមតិឡើយ។

**សំណួរ ៖ ក្នុងនាមជាសមាជិក គ.ជ.ប មួយរូប និង ផ្អែកតាមបទពិសោធន៍កន្លងមក ដែលលោកជំទាវ បណ្ឌិត បានធ្វើទស្សនកិច្ច ទៅជួបបងប្អូនស្ត្រី ជាប្រជាពលរដ្ឋសាមញ្ញ ជាបេក្ខនារី ឬជាមន្ត្រីបោះឆ្នោត តើលោកជំទាវ បណ្ឌិត បានសង្កេតឃើញថា មានការរីកចំរើនចំពោះស្ថានភាពរបស់ស្ត្រីដែរឬទេ?**

**ចម្លើយ ៖** ខ្ញុំបានកត់សំគាល់ឃើញថា ស្ត្រីដែលបំរើការក្នុងស្ថាប័នបោះឆ្នោត មានសកម្មភាពរស់រវើក និង ខិតខំព្យាយាម។ ពួកគេបំពេញការងារប្រកបដោយមនសិការខ្ពស់។ ទោះបីជាពួកគេមានសុឆន្ទៈយ៉ាងនេះក៏ដោយ ក៏ពួកគេទទួលរងនូវសំពាធសង្គមដែរ។ ខ្ញុំបានឆ្លងកាត់បទពិសោធន៍នេះ ដោយផ្ទាល់ មួយដងមួយកាលដែរ នៅស្រុកយើង និងនៅឯបរទេស ។ យើងត្រូវតែរឹងប៉ឹង និងបង្ហាញសមត្ថភាពដែលអាចធ្វើបាន។

យើងឃើញអ្វីៗកំពុងតែផ្លាស់ប្តូរដើម្បីឈានទៅរកភាពប្រសើររបស់ស្ត្រីខ្មែរ។ ខ្ញុំចាំបានថា ក្នុងទស្សវត្សទី៦០ គេមិនសូវឃើញមានស្ត្រីបង្ហាញខ្លួនក្នុងវេទិកាសង្គមទេ យើងអាចរាប់ចំនួនស្ត្រីក្នុងជួររដ្ឋាភិបាលដោយម្រាមដៃ។ បច្ចុប្បន្ននេះ ស្ត្រីទទួលកាន់តំណែងខ្ពស់ ក្នុងជួររដ្ឋាភិបាល និង ក្នុងវិស័យជំនួញច្រើនជាងសម័យមុន។ ចំពោះការបោះឆ្នោតនាឆ្នាំ ២០០២ បេក្ខជន ១៦%ជាស្ត្រី ហើយស្ត្រី ៨.៤% ត្រូវបានជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ បន្ទាប់ពីការបោះឆ្នោតហើយ កៅអីក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបែងចែកដល់ស្ត្រី។ ចំពោះការបោះឆ្នោតសកលនាឆ្នាំ ២០០៣ បេក្ខជន ២៥%ជាស្ត្រី ហើយមានស្ត្រីតែម្នាក់ក្នុងចំណោមដប់នាក់ បានជាប់ជាសមាជិកានៅរដ្ឋសភាជាតិ។ យើងមានស្ត្រី ១៣% ដែលបានជាប់ជាសមាជិកាព្រឹទ្ធសភាដែរ។

**សំណួរ ៖ ក្នុងនយោបាយ តើអ្វីទៅជាគុណភាពចំបងរបស់ស្ត្រី បើប្រៀបធៀបជាមួយនឹងបុរស? តើទង្វើរបស់ស្ត្រីជំរុញអោយពួកគេលើកឡើងនូវបញ្ហាដែលបុរសមិនដែលគិតដែរឬទេ?**

**ចម្លើយ ៖** នយោបាយចាប់ផ្តើមចេញពីផ្ទះ និងពីតំរូវការរបស់ស្ត្រី។ ស្ត្រីទទួលខុសត្រូវលើការងារផ្ទះសំបែង ដូចជា ម្ហូបអាហារ សុខភាព ការអប់រំ ។ល។ ពួកគេយល់ និងផ្តោតអារម្មណ៏ទៅលើបញ្ហានេះជានិច្ចជាកាល។ ជាទូទៅពួកគេមានប្រសិទ្ធភាព និងអំណាចក្នុងការដោះស្រាយបញ្ហាទាំងនេះនៅក្នុងរង្វង់គ្រួសារ ហើយគេក៏ធ្វើឱ្យសេចក្តីត្រូវការនេះក្លាយទៅជាទំរង់នយោបាយយកមកដោះស្រាយ នៅក្នុងភូមិ និង ឈានទៅដល់ឃុំ។ ពួកគេនិយាយ និងដោះស្រាយបញ្ហានេះដោយសុទ្ធចិត្ត មានន័យថា ពួកគេ មានភាពស្មោះស្ម័គ្រ និងអាចបញ្ចុះបញ្ចូលឱ្យគេយល់ដឹងអំពីបញ្ហាដែលគេលើកឡើង។ ដោយគេមានអត្តន្តរញ្ញាណនេះ ស្ត្រីផ្តល់ទស្សនៈជាក់លាក់ ដែលអាចបន្ថែមលើទស្សនៈ របស់បុរសបាន។

**សំណួរ ៖ នៅថ្ងៃទី ០៨ ខែ មីនា ទិវានារីអន្តរជាតិ នឹងត្រូវប្រារព្ធទូទាំងពិភពលោក។ ប្រសិនបើលោកជំទាវបណ្ឌិតមានឱកាស តើលោកជំទាវ នឹងផ្តាំផ្ញើអ្វី ដល់ស្ត្រីដែលចូលរួមក្នុងដំណើរការបោះឆ្នោត?**

**ចម្លើយ ៖** ខ្ញុំនឹងជំរាបពួកគេថា "គុណធម៌ជាសម្ផស្ស"។ បានន័យថា ប្រសិនបើគេមានចំណេះដឹងជ្រៅជ្រះ តែគេគ្មានគុណធម៌ នោះគេនឹងអាចមិនទទួលបានជោគជ័យ។ ចំណេះវិជ្ជា និងគុណធម៌ ត្រូវតែដើរជាមួយគ្នាដើម្បីជាកំលាំង និងជំនួយសំរាប់ស្ត្រី។ ខ្ញុំមានជំនឿថា ស្ត្រីអាចប្រើប្រាស់គុណធម៌សំរាប់ខ្លួនឯងផង និងសហគមន៍របស់ខ្លួនផង។ ក្រៅពីនេះ សូមជំរាបថា ៖

- វាសំខាន់ណាស់ដែលត្រូវខំប្រឹងស្វែងរកសុភមង្គលសំរាប់ខ្លួនឯងជាមុន នោះយើងនឹងអាចចែករំលែកសុភមង្គលនោះ ដល់អ្នកដែលនៅជុំវិញខ្លួនយើង។
- សូមកុំមានគំនិតអាត្មានិយម និង ចេះចែកអំណាចគ្នាដើម្បីធ្វើការ។
- ខ្ញុំមិននិយាយអំពីរឿងនយោបាយទេ ស្ត្រីត្រូវបំពេញការងារក្នុងលក្ខណៈវិជ្ជាជីវៈ ជាអ្នកចេះស្តាប់ ដើម្បីស្វែងយល់ឱ្យបានល្អគ្រប់ជ្រុងជ្រោយ និងជាអ្នកធ្វើការដោយមានគោលដៅប្រាកដនិយមព្រមទាំងមានហេតុផល ។
- ចេះសំរបសំរួលគ្នានៅពេលបំពេញការងារជាក្រុម និងទីបំផុតជាអ្នកដែលតែងតែពិគ្រោះយោបល់គ្នា។